ព្រះរាជាណាចក្រកម្ពុជា

Inform-សជណ: 30-10-14-សច-បល-P 113

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ០៥៥/១៤ អកក.រប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសកម្មករអណ្តែតចំនួន ០២ រូប ដើម្បីចូលបម្រើការងារជា កម្មករឃ្លាំងចំការដូង នៅការិយាល័យផ្គត់ផ្គង់សម្ភារនិងដឹកជញ្ជូន នៃនាយកដ្ឋានលទ្ធកម្ម ដូចខាងក្រោម :

* - **លក្ខណៈសម្បត្តិបេក្ខជន** :
  - បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
  - បៀវត្សរ៍ផ្តល់ជូន : ប្រាក់កម្រៃប្រចាំថ្ងៃ(ថ្ងៃធ្វើការ) ចំនួន ២៥.០០០ រ/នាក់/ថ្ងៃ (ម្ភៃប្រាំពាន់រៀល)
  - កម្រិតវប្បធម៌ : ចេះ អាននិងសរសេរ អក្សរខ្មែរបាន
  - បេក្ខជនត្រូវមាន កាយសម្បទានិងកម្លាំងមាំមួន ។

* - **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត)ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងលិខិតបញ្ជាក់ការសិក្សា ឬសញ្ញាប័ត្រចំណេះដឹងទូទៅ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

* - **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

* -**ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា